រក្សាសិទ្ធិ © ពត៌មាន :
© ២០០១ Project WorldReach © ២០០១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

025KH01A-01

ឫទ្ធានុភាពរបស់ព្រះអម្ចាស់ យេស៊ូគ្រីស្ត ដែលនៅក្នុងយើង



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

២៥

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

រឿងនិទានអំពីលោកត្រាន់ខាងក្រោមនេះ ត្រូវបានសរសេរឡើង តាមហេតុការណ៍ និងការសង្កេតឃើញនៅប្រទេសអាស៊ី ។ រឿងនេះបង្ហាញពីរបៀបដែលគ្រីស្តជនឈ្លាសវៃអាចឈ្នះលើឫទ្ធានុភាពរបស់ពួកអារក្ស ។ ពេលដែលអ្នកអានរឿងនេះ សូមរកមើលអ្វីៗដែលតែងតែរួមផ្សំជាមួយសកម្មភាពរបស់អារក្ស នៅកន្លែងដែលមនុស្សចាត់ទុកថាព្រះនៅឆ្ងាយ ដូច្នេះ ពួកគេក៏ប្រើប្រាស់ឫទ្ធានុ-ភាពរបស់វិញ្ញាណអាក្រក់ ។

សូមរកមើលសេចក្តីខាងក្រោមនេះ នៅក្នុងរឿងអំពីប៉ែងលី :

ពួកអារក្សឆ្លៀតធ្វើបាបអ្នកដែលមានជំនឿខុសឆ្គង

ពួកអារក្សតែងតែមករកមនុស្ស ដែលគោរពបូជាព្រះក្លែងក្លាយ ប្រើខ្សែកាថា ឬ គោរពរបស់គ្រប់ប្រភេទ ដែលគេជឿថាមានឫទ្ធានុភាពនៃអបិយ៍ជំនឿ ។ ព្រះគម្ពីរចែងថា ការថ្វាយបង្គំព្រះក្លែងក្លាយដូចគ្នានឹងការថ្វាយបង្គំអារក្សដែរ ។ (លេវីវិន័យ ១៧:២១, ជំរឿនប្រជាជន ២៥:៣, ១ កូរិនថូស ១០:២០, វិវរណៈ ៩:២០) ។

ជួយជនរងគ្រោះដោយសារអារក្ស អោយលន់តួសារភាពអំពើបាបរបស់ពួកគេ និងឈប់ប្រតិបត្តិតាមអបិយ៍ជំនឿដែលពួកគេធ្លាប់ធ្វើពីមុនមក និងពេលឥឡូវនេះ ។

ធ្វើឱ្យពួកគេជឿជាក់ថា ព្រះជាម្ចាស់តែងតែលើកលែងទោសឱ្យ ដោយសារព្រះគ្រីស្ត ហើយព្រះយេស៊ូមានឫទ្ធានុភាពខ្លាំងជាងពួកអារក្សទាំងអស់ រហូតដល់ព្រះអង្គបានឈ្នះទាំងស្រុង និងជារៀងរហូតលើពួកវា ដោយសារព្រះអង្គសុគតលើឈើឆ្កាង និង មានព្រះជន្មរស់ឡើងវិញ ។

កិច្ចការដែលត្រូវអនុវត្ត

- ព្រះជាម្ចាស់ផ្តល់អោយយើងមានគ្រឿងសស្ត្រាវុធសំរាប់ធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ ប្រឆាំងនឹងឫទ្ធានុភាពរបស់អារក្ស (អេភេសូ ៦:១០-២០) ។ អានដោយម៉ត់ចត់ អំពីគ្រឿងសស្ត្រាវុធទាំងនេះ រួចប្រើប្រាស់គ្រឿងសស្ត្រាវុធទាំងនេះទៅ ។

- តើអ្នកមានស្គាល់មនុស្ស ដែលគេមើលឃើញច្បាស់ថា នៅក្រោមអំណាចអារក្សដែរឬទេ ? បើពួកគេចង់បានរួចខ្លួនពីអារក្សវិញ សូមអធិស្ឋានសំរាប់ពួកគេ ក្នុងព្រះនាមព្រះ-យេស៊ូគ្រីស្ត ។ ដើម្បីជួយមនុស្សដួចនេះបាន ត្រូវអធិស្ឋានច្រើន និងតមអាហារ ព្រមទាំងទៅជួបនិយាយ និងអធិស្ឋានជាមួយមនុស្សនោះច្រើនដងទៀតផង ។

  គំរាមក្នុងព្រះនាមព្រះយេស៊ូ ឱ្យវិញ្ញាណអាក្រក់គ្រប់ប្រភេទដែលបង្ហាញខ្លួនតាមរបៀបជាក់ស្តែងណាមួយ ។ ប៉ុន្តែមិនត្រូវយកចិត្តទុកដាក់អំពីពួកអារក្សអោយហួសពីកិរិត ដែលព្រះយេស៊ូយកចិត្តទុកដាក់ចំពោះអារក្សទេ ។

ពួកអារក្សប្រើឫទ្ធានុភាព ដែលមានកំរិត ដើម្បីធ្វើអោយមានទីសំគាល់ភ្លែងភ្លាយ

មារសាតាំងប្រើទ្ធានុភាពរបស់វា ដើម្បីធ្វើអោយមានទីសំគាល់ និងការអស្ចារ្យភ្លែងភ្លាយ ។ ទីសំគាល់ និងការអស្ចារ្យភ្លែងភ្លាយទាំងនោះ នាំមនុស្សអោយបែរចេញពីព្រះជាម្ចាស់ និងពីសេចក្តីពិតរបស់ព្រះបន្ទូលព្រះអង្គ (សេរីភាព ៧, យ៉ូប ជំពូក ១ និង ២, វិវរណៈ ១៦:១៤) ។ មនុស្សដែលភ័យខ្លាចវិញ្ញាណទាំងឡាយ (ខ្មោចព្រាយបិសាច) ខិតខំប្រើប្រាស់វិញ្ញាណទាំងនោះដោយធ្វើពិធីផ្សេងៗ ឬ ពាក់ខ្សែកាថា ឬ រកគ្រូមន្តអាគម ។ ការភ័យខ្លាច និងអំពើដែលមនុស្សធ្វើនោះ នាំអោយមនុស្សធ្លាក់ចុះទៅជាមានទំនាក់ទំនងជាមួយសាតាំង ។

ទោះបីជាមារសាតាំង និងពួកអារក្សមានឫទ្ធានុភាពក៏ដោយ ក៏ព្រះជាម្ចាស់កិរិតឫទ្ធានុភាពរបស់ពួកវាដែរ ។ ឧទាហរណ៍ ពួកអារក្សមិនអាចបំបែកពួកអ្នកជឿចេញពីព្រះគ្រីស្តបាន ជាដាច់ខាត (រ៉ូម ៨:៣៨-៣៩) ។ មនុស្សក្នុងពិភពលោកច្រើនណាស់ បានជឿលើព្រះយេស៊ូ ដោយសារបានឃើញឫទ្ធានុភាពជាក់ស្តែងរបស់ព្រះអង្គលើវិញ្ញាណអាក្រក់ទាំងឡាយ ។

ពួកអារក្សចង់អោយមនុស្សយកចិត្តទុកដាក់ចំពោះពួកវាខ្លាំងណាស់

មារសាតាំងធ្លាក់ចុះពីស្ថានបរមសុខ ពីព្រោះតែវាមានបំណងចង់តម្កើងខ្លួនខ្លាំងពេក ។ មារសាតាំងចង់អោយគេយកចិត្តទុកដាក់ចំពោះខ្លួន ដូចជាគេយកចិត្តទុកដាក់ចំពោះព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតដែរ (អេសាយ ជំពូក ១៤) ។ ពួកអារក្សនាំមនុស្សអោយភាន់ច្រឡំទាក់ទងនឹងពួកវា តាមរយៈប្រពៃណី មន្តអាគម ពិធីសាសនាទាំងឡាយ ។ល។ ។ ព្រះយេស៊ូមានបន្ទូលប្រាប់ពួកសិស្សថា កុំអោយចាប់អារម្មណ៍អំពីសកម្មភាពអារក្សខ្លាំងពេក តែត្រូវជាប់ចិត្តនឹងមេត្រីភាព ដែលអ្នកទាំងអស់មានជាមួយព្រះ-យេស៊ូវិញ (លូកា ១០:១៧-២០) ។ សិស្សរបស់ព្រះយេស៊ូមិនដែលខំស្វែងរកអារក្សទេ ។ ប៉ុន្តែ ពួកគេគំរាមពួកអារក្ស នៅពេលដែលពួកគេឃើញអារក្សធ្វើបាបមនុស្សរងគ្រោះ (ម៉ាកុស ១:២១-២៧) ។

ខ្មោចក៏ចេញទៅ ដោយស្រែកជាខ្លាំង ឯកូនប្រុសក៏ងើបអង្គុយហើយក្រឡេកមើលជុំវិញខ្លួន ។ គេនិយាយប្រាប់ឪពុកម្តាយគេ និងគ្រីស្តជនជាភ្ញៀវថា គ្រូកំណើតរបស់គេប្រាប់អោយគេទៅលោតទឹកសំឡាប់ខ្លួនក្នុងស្ទឹង ។

គ្រីស្តជនប្រាប់គ្រួសារនោះថា÷



គ្រីស្តជនដឹងភ្លាមថា នេះជាសំឡេងខ្មោច និយាយចេញពីមនុស្ស ឈឺមក ។ គាត់ក៏បញ្ជាទៅខ្មោចថា÷



ពួកអារក្សនិយាយតែពាក្យភូតកុហក ដែលបំផ្លាញមនុស្ស

មារសាតាំងជាឪពុកនៃអ្នកកុហក (យ៉ូហាន ៨:៤៤) ។ តាមធម្មតាពាក្យភូតកុហរបស់មារសាតាំងទាំងនេះ ដែលព្រះគម្ពីរហៅថាជា «សេចក្តីប្រៀនប្រដៅរបស់អារក្ស» នោះ ធ្វើឱ្យមនុស្សមានការប្រព្រឹត្ត ដែលបំផ្លាញមនុស្សខ្លួនឯង ដូចជាការចៀសវាង មិនបរិភោគចំណីអាហារ ដែលនាំអោយមានសុខភាពល្អ (១ ធីម៉ូថេ ៤:១-៥) ។

នៅពេលដែលពួកអារក្សបង្ហាញខ្លួនអោយមនុស្សមើលឃើញ សកម្មភាពរបស់ពួកវា ពួកអ្នកជឿលើព្រះគ្រីស្តអាចបញ្ជាពួកវាក្នុងព្រះនាមព្រះយេស៊ូអោយចេញទៅ (កិច្ចការ ១៦:១៧-១៨)។ មនុស្សដែលត្រូវអារក្សគ្រប់គ្រង នៅពេលដឹងខ្លួនត្រឹមត្រូវវិញ ត្រូវលន់តួសារភាពអំពើបាបរបស់ខ្លួន លះបង់ឈប់ប្រតិបត្តិតាមអបិយ៍ជំនឿគ្រប់យ៉ាង ហើយទុកចិត្តលើព្រះយេស៊ូ (កិច្ចការ ១៩:១៣-២០) ។ យើងត្រូវអោយគេជឿជាក់ថា ព្រះគ្រីស្តបានឈ្នះមារសាតាំង និងកងទ័ពរបស់វាពេញលេញ និងជារៀងរហូតដោយសារការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ (កូឡូស ២:១៥) ។

នៅពេលអានរឿងនេះ សូមនឹកចាំជានិច្ចពីសេចក្តីដែលអ្នកត្រូវរក :

- ពួកអារក្សឆ្លៀតធ្វើបាបអ្នកមានជំនឿខុសឆ្គង (ការថ្វាយបង្គំព្រះក្លែងក្លាយ ឬ ការប្រតិបត្តិតាមអបិយ៍ជំនឿ) ។
- ពួកអារក្សប្រើឫទ្ធានុភាព ដែលមានកិរិត ដើម្បីធ្វើអោយមានទីសំគាល់ក្លែងក្លាយ ។
- ពួកអារក្សចង់អោយមនុស្សយកចិត្តទុកដាក់ ចំពោះពួកវាខ្លាំងណាស់ ។
- ពួកអារក្សនិយាយតែពាក្យភូតកុហក ដែលបំផ្លាញមនុស្ស ។

នៅពេលដែលជួបនឹងឫទ្ធានុភាពធំធេងរបស់ព្រះយេស៊ូ ពួកអារក្សត្រូវតែចាញ់ ។ (យើងរំដោះមនុស្សអោយរួចពីការជិះជាន់របស់អារក្ស ដោយសារព្រះនាមព្រះយេស៊ូ ជួយពួកគេអោយលន់តួសារភាពអំពើបាបរបស់ខ្លួន ហើយលះបង់ការប្រតិបត្តិតាមអបិយ៍ជំនឿគ្រប់យ៉ាង) ។

កូនប្រុសនោះ ក៏ចាប់ផ្តើមកំរើកខ្លួន ហើយនិយាយសម្តែងធំគ្រលរថា÷



© Project WorldReach © SEAN

គ្រីស្តជននោះ ក៏អធិស្ឋានថា÷



រឿងរបស់ លី ប៉ែង :

ពីមុននាងភូ និង ប្តីនាងឈ្មោះត្រាន់ មានកូនម្នាក់កើតមកស្លាប់ភ្លាម ហើយកូនពីរនាក់ទៀត ស្លាប់មុនអាយុប្រាំឆ្នាំ ។ នាងភូទើបនឹងកើតកូនង៉ែតម្នាក់ទៀត ដែលនាង និងប្តីដាក់ឈ្មោះថាប៉ែង ។ នាងភូនិយាយប្រាប់ប្តីនាងថា÷



លោកត្រាន់បានជាវខ្សែកាថាយកមកធ្វើខ្សែចង្កេះ និងខ្សែកអោយកូនពាក់ ។

ប៉ុន្តែ បងខ្លាចតែខ្សែកាថាធម្មតានេះ មិនអាចការពារកូនយើងបានទេ ។



គ្រាន់ក៏ទៅជួបនឹងគ្រូមន្តអាគម ដើម្បីឱ្យគ្រូនោះប្រាប់គាត់ពីរបៀបការពារកូនគាត់ ។ គ្រូមន្តអាគមប្រាប់គាត់ឱ្យធ្វើស្លាធមិ ដោយយកកូនចេកមួយកង់តូច ឬ ផ្លែដូងទុំទាំងសំបកមួយ មកដោតស្លឹកម្ជួបួន ឬ ប្រាំសន្លឹក និងចំណិតស្លាក្រៀមបី ឬ បួនចំណិតមួយគូ សំរាប់ជុតធូបថ្វាយគ្រូកំណើតរបស់កូននោះរាល់ល្ងាច ដើម្បីបួងសួងសុំអោយគ្រូកំណើតរបស់កូននោះការពារកូននោះ ។

ពុំពីរនាក់ប្តីប្រពន្ធនេះ បានបួងសួងសុំអោយគ្រូកំណើតវាជួយ និងបានទៅរកគ្រូបុរាណអោយជួយ ។ គ្រូទាំងនោះបានធ្វើពិធីជាច្រើន ដើម្បីរំដោះវា ។



ខ្ញុំសូមនិយាយប្រាប់ពូពីព្រះរបស់ខ្ញុំ ដែលមានព្រះនាមថាព្រះយេស៊ូ ។ ពេលដែលព្រះយេស៊ូយាងមកលើផែនដី ព្រះអង្គបានបង្ហាញថា ព្រះអង្គមានទ្វានុភាព ។ ព្រះអង្គបានប្រោសអ្នកជំងឺឱ្យជា ធ្វើឱ្យខ្ចល់ព្យុះសប់ដេញខ្មោចចេញពីមនុស្ស ព្រមទាំងប្រោសមនុស្សស្លាប់អោយរស់ឡើងវិញផង ។ ព្រះអង្គបានសុគត ហើយត្រូវគេបញ្ចុះព្រះអង្គទៅក្នុងផ្នូរបីថ្ងៃ ប៉ុន្តែ ព្រះអង្គមានព្រះជន្មរស់ឡើងវិញនៅថៃទីបី ។ ពូមិនបាច់ធ្វើពិធីអ្វីដើម្បីសូមអោយព្រះអង្គជួយទេ ។ សូមគ្រាន់តែជឿថា ពិតជាមានព្រះអង្គមែន ហើយជឿទុកចិត្តថា ព្រះអង្គមានគ្រប់ព្រះចេស្តាទៅ ។ ខ្ញុំនឹងទូលសូមឱ្យព្រះជាម្ចាស់រំដោះកូនប្រុសពូ និង ដេញខ្មោចចេញពីជីវិតកូនពូចេញ ។



នាងភូ និងត្រាន់ធ្វើតាមពាក្យរបស់គ្រូមន្តអាគម ហើយនាំគ្នាធ្វើ
ស្លាធមិមួយគូ ដែលគាត់ដុតធូបបីសរសៃដោត និងបួងសួងសុំឱ្យ
គ្រូកំណើតរបស់កូនជួយការពារកូនរាល់ល្ងាច ។





ច្រើនឆ្នាំក្រោយមក ត្រាន់បានអង្គុយធមិបួងសួងឃើញត្រូកំណើត
របស់ប៉ែងនិយាយប្រាប់គាត់ថា÷



ថ្ងៃមួយ គ្រីស្តជនម្នាក់ ដើរកាត់មុខផ្ទះត្រាន់ និង នាងភូ ។
ត្រាន់តែងតែចំអកអោយគ្រីស្តជននោះ ប៉ុន្តែ ពេលនោះគាត់ត្រូវ
ការជំនួយខ្លាំងណាស់ ។ ត្រាន់ក៏ស្រែកហៅគ្រីស្តជននោះថា÷



© Project WorldReach © SEAN

គ្រាន់ និងភ្ជួរត់ទៅរកគ្រូបុរាណអោយជួយ ។ គ្រូទាំងនោះបានធ្វើពិធីជាច្រើនលើកូនប្រុសគាត់ តែកូនគាត់មិនបានធូរស្រាលសោះ។



ប៉ែងក៏ធ្វើតាមការមើលឃើញរបស់ឪពុក ហើយបួងសួងសុំអោយគ្រូកំណើតការពារខ្លួនស្ទើរតែរាល់ថ្ងៃ ។ ពីមួយថ្ងៃទៅមួយថ្ងៃ អាកប្បកិរិយារបស់ប៉ែងចេះតែប្លែកទៅៗ ។ ពេលខ្លះប៉ែងនិយាយដោយសំលេងធំគ្រលរ និងនិយាយពាក្យព្រហើនកោងកាច ។ ប៉ែងប្រាប់ឪពុកម្តាយខ្លួនថា គ្រូកំណើតរបស់ខ្លួនប្រាប់អោយខ្លួននិយាយដូច្នេះ ។

ប៉ែងឈប់ស្តាប់តាមពាក្យឪពុកម្តាយ និង មិត្តភ័ក្តិជាច្រើនខែ ហើយរង់ចាំស្តាប់ និងធ្វើតាមតែគ្រូកំណើតរបស់ខ្លួន ។ យប់មួយ គ្រូកំណើតប្រាប់ប៉ែងថា÷



© Project WorldReach © SEAN

ព្រឹកឡើង គ្រាន់ទៅមាត់ស្ទឹងដែលនៅក្បែរផ្ទះគាត់ ដើម្បីរកត្រី ។ គាត់ស្រាប់តែឃើញកូនប្រុសគាត់ដេកស្លុកនៅមាត់ស្ទឹង ។ បបូរមាត់កូនគាត់ស្លេកគ្មានឈាម ហើយកូនគាត់សន្លប់មិនដឹងខ្លួនប៉ុន្តែ នៅមានដង្ហើមនៅឡើយ ។



គ្រាន់លើកកូនយកមកផ្ទះវិញ ។ នាងភ្ញាស្រែកទ្រហោយំថា÷



© Project WorldReach © SEAN